# NAPLAN តាមក្រដាស – ព័ត៌មានសម្រាប់មាតាបិតា និងអ្នកថែទាំ

Khmer

NAPLAN
NATIONAL ASSESSMENT PROGRAM
Literacy and Numeracy

2018

## ហេតុអ្វីបានជាសិស្សធ្វើតេស្ត NAPLAN?

កម្មវិធីជាតិវាយតម្លៃសមត្ថភាពសិក្សា – អក្ខរកម្មនិងលេខនព្វន្ត (NAPLAN) វាយតម្លៃបំណិនអក្ខរកម្មនិងលេខនព្វន្ត ដែលសំខាន់ចាំបាច់សម្រាប់កុមាររាល់រូប ក្នុងការវិវឌ្ឍតាមរយៈសាលារៀននិងការរស់នៅ។

សិស្សថ្នាក់ទី 3, 5, 7 និង 9 ចូលរួមក្នុងតេស្ត NAPLAN ប្រចាំឆ្នាំ ក្នុងផ្នែកអានសរសេរ និងចំណេះដឹងទូទៅនៃភាសា (ប្រកបអក្សរ វេយ្យាករណ៍ និងវណ្ណយុត្តិ) និងលេខនព្វន្ត។

តេស្តទាំងនេះផ្តល់ឱ្យមាតាបិតានិងសាលារៀននូវការយល់ដឹងថាតើសិស្សនីមួយៗកំពុងបំពេញលទ្ធផលសិក្សាយ៉ាងណាដែរនៅពេលធ្វើតេស្ត។ តេស្ត NAPLAN គឺគ្រាន់តែជាទិដ្ឋភាពមួយនៃដំណើរការវាយតម្លៃនិងធ្វើរបាយការណ៍របស់សាលារៀនប៉ុណ្ណោះ វាមិនជំនួសឱ្យការវាយតម្លៃជាបន្តបន្ទាប់ដែលធ្វើដោយគ្រូបង្រៀនអំពីការបំពេញលទ្ធផលសិក្សារបស់សិស្សឡើយ។

តេស្ត NAPLAN ក៏ផ្តល់ឱ្យសាលារៀន អាជ្ញាធរអប់រំ និងរដ្ឋាភិបាលផងដែរនូវព័ត៌មានអំពីថាតើកម្មវិធីអប់រំកំពុងដំណើរការយ៉ាងណាដែរ និងថាតើពលរដ្ឋអូស្ត្រាលីវ័យក្មេងទាំងឡាយកំពុងបំពេញបាននូវលទ្ធផលអប់រំដ៏សំខាន់ក្នុងផ្នែកអក្ខរកម្មនិងលេខនព្វន្តឬទេ។

## តើនឹងធ្វើតេស្តអំពីអ្វី?

NAPLAN វាយតម្លៃបំណិនអក្ខរកម្មនិងលេខនព្វន្តដែលសិស្សកំពុងសិក្សា តាមរយៈកម្មវិធីសិក្សាប្រក្រតីរបស់សាលារៀន។ អាជ្ញាធរអប់រំរបស់រដ្ឋនិងមិនមែនរបស់រដ្ឋទាំងអស់បានរួមចំណែកដល់ការបង្កើតសម្ភារឯកសារ NAPLAN ។

ដើម្បីផ្តល់ជូនលោកអ្នកនូវគំនិតខ្លះៗអំពីទម្រង់នៃតេស្តនេះ សូមអានសំណួរជាឧទាហរណ៍នៅតាម nap.edu.au/naplanexample

## តើខ្ញុំអាចជួយកូនខ្ញុំត្រៀមខ្លួនសម្រាប់ NAPLAN តាមវិធីណា?

ជួយកូនលោកអ្នកត្រៀមខ្លួនសម្រាប់ NAPLAN តាមរយៈការផ្តល់ទំនុកចិត្តជាថ្មីដល់កូនថា តេស្តទាំងនេះគឺគ្រាន់តែជាផ្នែកមួយនៃកម្មវិធីសាលារៀនរបស់ខ្លួនប៉ុណ្ណោះ និងតាមរយៈការរំលឹកកូននៅថ្ងៃធ្វើតេស្តឱ្យខិតខំអស់ពីសមត្ថភាពរបស់ខ្លួន។ គ្រូបង្រៀននឹងធានាបន្សាំសិស្សជាមួយនឹងប្រភេទនៃសំណួររបស់តេស្ត ហើយនឹងផ្តល់ជំនួយនិងការណែនាំសមស្រប។

ACARA មិនស្នើឱ្យប្រើប្រាស់សេវាកម្មផ្តល់ដោយអ្នកផ្តល់ការហ្វឹកហ្វឺន ឬការរៀបចំហួសប្រមាណឡើយ។ NAPLAN មិនមែនអំពីការប្រឡងជាប់ឬធ្លាក់ទេ ប៉ុន្តែវាជាការវាយតម្លៃការរីកចម្រើននៃការសិក្សា។

## ការចូលរួមក្នុង NAPLAN

មានការរំពឹងថា សិស្សទាំងអស់ដែលរៀននៅថ្នាក់ទី 3, 5, 7 និង 9 ត្រូវចូលរួមក្នុងការធ្វើតេស្ត NAPLAN ប្រចាំឆ្នាំ។

សិស្សមានពិការភាពអាចមានសិទ្ធិទទួលការកែតម្រូវដែលឆ្លុះបញ្ចាំងជំនួយដែលផ្តល់ឱ្យជាធម្មតា សម្រាប់ការវាយតម្លៃនៅថ្នាក់រៀន។ នៅពេលត្រូវអនុវត្តលោកអ្នកគួរពិភាក្សាជាមួយគ្រូបង្រៀនរបស់កូនលោកអ្នកជាដំបូងសិន អំពីការប្រើកំណែតម្រូវពិការភាពណាមួយសម្រាប់កូនលោកអ្នក។ ការលើកលែងផ្លូវការអាចផ្តល់ឱ្យសិស្សដែលមានពិការភាពបញ្ញាខ្លាំងក្លា និង/ឬ ស្ថានភាពកើតមានរួមគ្នាដ៏ធំដុំ ឬសម្រាប់សិស្សដែលទើបមកដល់ប្រទេសអូស្ត្រាលីហើយមានសាវតារមិននិយាយអង់គ្លេស។

នាយកសាលារបស់កូនលោកអ្នក និងអាជ្ញាធរគ្រប់គ្រងតេស្តប្រចាំតំបន់របស់លោកអ្នក អាចផ្តល់ជូនលោកអ្នកនូវព័ត៌មានបន្ថែមអំពីកំណែតម្រូវពិការភាព ឬដំណើរការដែលត្រូវការសម្រាប់ទទួលការលើកលែងផ្លូវការ។

## តើកូនខ្ញុំនឹងធ្វើតេស្ត NAPLAN តាមក្រដាស ឬតាមអនឡាញ?

កូនលោកអ្នកនឹងធ្វើតេស្ត NAPLAN តាមក្រដាស នៅឆ្នាំ 2018។

ប៉ុន្តែ កុមារនៅតាមសាលារៀនខ្លះទៀតនៅក្នុងប្រទេសអូស្ត្រាលីអាចធ្វើតេស្ត NAPLAN តាមអនឡាញនៅឆ្នាំនេះ។ រដ្ឋមន្ត្រីអប់រំថ្នាក់សហព័ន្ធ រដ្ឋ និងដែនដី បានយល់ព្រមថា NAPLAN នឹងប្តូរទៅកាន់អនឡាញនៅពេលពីរទៅបីឆ្នាំខាងមុខនេះ។ អាជ្ញាធរអប់រំរដ្ឋនិងដែនដី នឹងសម្រេចនូវពេលដែលសាលារៀនរបស់ខ្លួនប្តូរទៅអនឡាញ។

ដោយសារតែសិស្សទាំងអស់ទទួលសំណួរដែលធ្វើតេស្ត ភាពលំបាកដែលមានទំហំដូចគ្នា ដោយមិនគិតអំពីថាតើសិស្សធ្វើតេស្តតាមអនឡាញឬតាមក្រដាសទេនោះ លទ្ធផលសម្រាប់ទម្រង់ទាំងពីរនឹងត្រូវបានរាយការណ៍តាមរង្វាស់ខ្នាតវាយតម្លៃ NAPLAN ដូចគ្នា។

ដើម្បីទទួលព័ត៌មានបន្ថែមអំពីអនឡាញ NAPLAN សូមបើកមើលនៅឯ nap.edu.au/online-assessment

## តើមានអ្វីកើតឡើងបើកូនខ្ញុំមិនទៅសាលារៀន នៅថ្ងៃធ្វើតេស្ត?

នៅពេលមានលទ្ធភាព សាលារៀនអាចរៀបចំឱ្យសិស្សរៀងខ្លួនទាំងឡាយ ដែលមិនទៅសាលារៀននៅពេលធ្វើតេស្ត បំពេញតេស្តដែលខកខាននៅពេល មួយទៀតក្នុងអំឡុងសប្ដាហ៍ធ្វើតេស្ត។ សិស្សនីមួយៗគ្មានការអនុញ្ញាតឱ្យធ្វើ តេស្តនៅក្រោយថ្ងៃសុក្រ ទី 18 ឧសភា 2018 ឡើយ។

## តារាងពេលវេលាធ្វើតេស្ត NAPLAN ឆ្នាំ 2018

| | អង្គារ<br>15 ឧសភា | ពុធ<br>16 ឧសភា | ព្រហស្បតិ៍<br>17 ឧសភា |
|---|---|---|---|
| **ថ្នាក់ទី 3** | ចំណេះដឹងភាសាទូទៅ<br>40 នាទី<br>........................<br>ការសរសេរ<br>40 minutes | ការអាន<br>45 នាទី | លេខនព្វន្ត<br>45 នាទី |
| **ថ្នាក់ទី 5** | ចំណេះដឹងភាសាទូទៅ<br>40 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>50 នាទី | លេខនព្វន្ត<br>50 នាទី |
| **ថ្នាក់ទី 7** | ចំណេះដឹងភាសាទូទៅ<br>45 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>65 នាទី | លេខនព្វន្ត<br>60 នាទី |
| **ថ្នាក់ទី 9** | ចំណេះដឹងភាសាទូទៅ<br>45 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>65 នាទី | លេខនព្វន្ត<br>60 នាទី |

## តើលទ្ធផលបំពេញការសិក្សារបស់កូនខ្ញុំត្រូវបាន វាស់វែងតាមរបៀបណា?

លទ្ធផលបំពេញការសិក្សារបស់សិស្សនីមួយៗត្រូវបានបង្ហាញនៅលើរង្វាស់ ខ្នាតជាតិសម្រេចបានសម្រាប់តេស្តនីមួយៗ។ លទ្ធផលនៅតាមស្តង់ដារជាតិ អប្បបរមាបង្ហាញថា សិស្សបានបង្ហាញឱ្យឃើញបំណិនអក្ខរកម្មនិងលេខ នព្វន្ត ដែលចាំបាច់ដើម្បីចូលរួមពេញលេញក្នុងកម្រិតថ្នាក់នោះ។ លទ្ធផល បំពេញការសិក្សារបស់សិស្សនីមួយៗអាចត្រូវបានប្រៀបធៀបនឹងលទ្ធផល បំពេញការសិក្សាជាមធ្យមរបស់សិស្សទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី។

សាលារៀនរបស់កូនលោកអ្នកនឹងចេញរបាយការណ៍ NAPLAN មួយនៅ ពេលក្រោយមកទៀតនៅក្នុងឆ្នាំដដែល។ បើលោកអ្នកមិនបានទទួលរបាយ ការណ៍នេះទេ លោកអ្នកគួរទាក់ទងសាលារៀនរបស់កូនលោកអ្នក។

## តើលទ្ធផលនៃតេស្ត NAPLAN ត្រូវបានប្រើ យ៉ាងណាដែរ?

- សិស្សនិងមាតាបិតាអាចប្រើលទ្ធផលនីមួយៗដើម្បីពិភាក្សាការរីកចម្រើន ជាមួយគ្រូបង្រៀន។
- គ្រូបង្រៀនប្រើលទ្ធផលដើម្បីជួយគាត់ក្នុងការរកមើលដឹងសិស្សទាំងឡាយ ដែលត្រូវការកិច្ចការរឹតតែលំបាក ឬជំនួយបន្ថែម។
- សាលារៀនប្រើលទ្ធផលដើម្បីរកមើលដឹងចំណុចខ្លាំងនិងចំណុចខ្សោយនៅ ក្នុងកម្មវិធីបង្រៀន និងដើម្បីកំណត់គោលដៅក្នុងអក្ខរកម្មនិងលេខនព្វន្ត។
- ប្រព័ន្ធសាលារៀនប្រើលទ្ធផលដើម្បីពិនិត្យឡើងវិញនូវកម្មវិធីនានានិងជំនួយ ដែលផ្ដល់ដោយសាលារៀន។
- សហគមន៍អាចមើលលទ្ធផល NAPLAN សាលារៀនជាមធ្យមនៅឯ myschool.edu.au

## តើទីណាដែលខ្ញុំអាចទទួលព័ត៌មានបន្ថែម?

ដើម្បីទទួលព័ត៌មានបន្ថែមអំពី NAPLAN៖

- ទាក់ទងសាលារៀនរបស់កូនលោកអ្នក
- ទាក់ទងអាជ្ញាធរគ្រប់គ្រងតេស្តក្នុងតំបន់លោកអ្នកនៅឯ nap.edu.au/TAA
- បើកមើល nap.edu.au

ដើម្បីទទួលព័ត៌មានអំពីរបៀបដែល ACARA មើលខុសត្រូវព័ត៌មានផ្ទាល់ខ្លួន សម្រាប់ NAPLAN សូមបើកមើល nap.edu.au/naplanprivacy